ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អគ្គនាយកដ្ឋានកសិកម្ម

# ដំណាំមន

## MULBERRY



រៀបចំដោយ: នាយកដ្ឋានដំណាំឧស្សាហកម្ម

AFACI
Asian Food & Agriculture
Cooperation Initiative

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អគ្គនាយកដ្ឋានកសិកម្ម

# ដំណាំមន

## MULBERRY

រៀបចំដោយ: នាយកដ្ឋានដំណាំឧស្សាហកម្ម
ឆ្នាំ២០១៥ បោះពុម្ពលើកទី១

# ក្រុមការងាររៀបចំចងក្រងឯកសារ

## អ្នកត្រួតពិនិត្យ និងផ្តល់យោបល់កែសម្រួល

១. លោក ខាន់ សំបូរ ប្រធាននាយកដ្ឋានដំណាំឧស្សាហកម្ម
២. លោក សុក វណ្ណា អនុប្រធាននាយកដ្ឋានដំណាំឧស្សាហកម្ម

## អ្នករៀបចំខ្លឹមសារបច្ចេកទេស

១. លោក យិន ច័ន្ទសុធី ប្រធានការិយាល័យដំណាំផ្តល់ប្រេង សរសៃ និងដំណាំមានសារជាតុញៀន នៃនាយកដ្ឋានដំណាំឧស្សាហកម្ម
២. លោក ម៉េង ឫទ្ធា មន្ត្រីបច្ចេកទេសការិយាល័យ រដ្ឋបាល ផែនការ គណនេយ្យ និងសហប្រតិបត្តិការអន្តរជាតិ នៃនាយកដ្ឋានដំណាំឧស្សាហកម្ម

## អ្នកវាយអត្ថបទ

១. កញ្ញា ទិព្វ ដាវ អនុប្រធានការិយាល័យរដ្ឋបាល ផែនការ គណនេយ្យ និងសហប្រតិបត្តិការអន្តរជាតិ នៃនាយកដ្ឋានដំណាំឧស្សាហកម្ម

## មាតិកា


១.សេចក្ដីផ្ដើម ..... ០១
២. ស្ថានភាពទូទៅនៃដំណាំមន ..... ០១
២.១ ដើមកំណើត និងប្រវត្តិដំណាំមន ..... ០២
២.២ ស្ថានភាពដំណាំមននៅលើពិភពលោក ..... ០២
២.៣ ស្ថានភាពដំណាំមននៅប្រទេសកម្ពុជា ..... ០២
២.៤ សារៈប្រយោជន៍ដំណាំមន ..... ០៣
២.៥ ពូជដំណាំមន ..... ០៣
២.៦ ទិន្នផលស្លឹក ..... ០៤
២.៧ គុណភាពស្លឹក ..... ០៤
២.៨ ភាពស៊ាំនៃជំងឺ និងគ្រោះធម្មជាតិ ..... ០៤
៣. លក្ខខ័ណ្ឌបរិស្ថាននៃដំណាំមន ..... ០៤
៣.១ សីតុណ្ហភាព ..... ០៤
៣.២ ពន្លឺ ..... ០៤
៣.៣ សំណើម ..... ០៤
៣.៤ តម្រូវការទឹក ..... ០៥
៣.៥ ដី ..... ០៥
៤.លក្ខណៈរូបសាស្ត្រនៃដំណាំមន ..... ០៥
៤.១ លក្ខណៈដើម ..... ០៥
៤.២ លក្ខណៈស្លឹក ..... ០៥
៤.៣ លក្ខណៈផ្កា ..... ០៥
៤.៤ លក្ខណៈផ្លែ ..... ០៥
៤.៥ លក្ខណៈឬស ..... ០៦
៥.ការបន្តពូជរបស់ដំណាំមន ..... ០៦
៦.ការបង្កើតចំការដំណាំមន ..... ០៧
៦.១ វិធីសាស្ត្រដាំ ..... ០៧
ក.ការរៀបចំរណ្ដៅ ..... ០៧
ខ.ការដាំ ..... ០៧
គ.ប្រភេទនៃការដាំមន ..... ០៧
ឃ.ចន្លោះគុម្ព ..... ០៧
ង.ការកំណត់ចន្លោះគុម្ពផ្អែកលើវិធីសាស្ត្រកាត់ ..... ០៧
៦.២ ការអនុវត្តនៅតំបន់ត្រូពិច ..... ០៨
ក. វិធីសាស្ត្រ ..... ០៩
៧.ការពត់រាង( ការតាក់តែងដើមឆ្នាំដំបូង ) ..... ០៩
៧.១ ទំរង់នៃការកាត់កំពស់ដើមទាប ..... ០៩
៧.២ ការពត់រាង( ការតាក់តែងដើម )ក្នុងករណីដែលការដាំផ្អៀង ..... ០៩

ក. នៅចន្លោះ១-៤ខែបន្ទាប់ពីដាំ..........០៩
ខ. ចាប់ពីអាយុ៩ខែបន្ទាប់ពីដាំ..........១០
៨.ការតាក់តែងមែក..........១០
៨.១ ប្រភេទនៃការតាក់តែងមែក..........១០
៨.២ គោលការណ៍កែសម្រួលដើមដែលនៅសល់..........១១
៨.៣ វិធីសាស្រ្តកាត់មែក..........១១
៩.ការប្រើប្រាស់ជី..........១១
៩.១ តំបន់ត្រូពិច..........១១
៩.២ វិធីសាស្រ្តប្រើប្រាស់..........១២
១០.ការគ្រប់គ្រងទឹក..........១២
១១.ការគ្រប់គ្រងស្មៅ និងវិធានការការពារ..........១២
១១.១ វិធានការគីមី..........១៣
១១.២ វិធានការក្សេត្រសាស្រ្ត..........១៣
១២.ការប្រមូលផល..........១៣
១២.១ វិធីសាស្រ្តបេះស្លឹក..........១៣
១២.២ វិធីសាស្រ្តកាត់យកមែក..........១៣
១២.៣ វិធីសាស្រ្តតាក់តែងមែកសំរាប់កូនដង្ហូវទើបញាស់..........១៤
១៣.ការប្រមូលផលនៅតំបន់ត្រូពិច និងការតាក់តែងមែក..........១៥
១៣.១ ចាប់ពីដាំរហូតដល់ពេលប្រមូលផលដំបូង..........១៥
១៣.២ វិធីសាស្រ្តដាំដំណាំចំរុះ..........១៥
១៣.៣ ការប្រមូលផល..........១៦

# ការដាំដុះដំណាំមន

## ១.សេចក្តីផ្តើម

ស្លឹកមនគឺជាអាហារមូលដ្ឋានសម្រាប់ដង្កូវនាងមានឈ្មោះថា *Bombyx mori* ។ ដង្កូវនាងប្រភេទនេះ ចិញ្ចឹមខ្លួនលើការស៊ីចំណីស្លឹកមនតែមួយមុខគត់ (មនMorus)។

គោលបំណងនៃការដាំដុះមនឱ្យបានល្អ គឺដើម្បីផលិតឱ្យបានច្រើននូវបរិមាណស្លឹកមនដែលមានគុណភាព និងផ្ទុកនូវសារធាតុចិញ្ចឹមខ្ពស់។ ដើម្បីបង្កើនផលិតផលស្លឹកមន ព្រមទាំងកាត់បន្ថយតម្លៃផលិតកម្ម ត្រូវមានការពឹងផ្អែកលើការអនុវត្តសកម្មភាពបច្ចេកទេសជាច្រើនដូចជា ការគិតពីសេដ្ឋកិច្ចនៃបរិមាណជីត្រូវប្រើប្រាស់ ការតាក់តែងមែក និងការជ្រើសយកកម្មវិធីស្រោចស្រពសមស្រប។ បន្ថែមលើនេះទៀត ត្រូវសិក្សាពីទិដ្ឋភាពទូទៅនៃការដាំដំណាំ និងសិក្សាពីលទ្ធភាពផលិតស្លឹករបស់ដំណាំមនតាមលក្ខណៈសេដ្ឋកិច្ច។

ដោយមានការទទួលយកនូវបច្ចេកទេសនៃផលិតកម្មដំណាំមនតាមបែបវិទ្យាសាស្រ្ត គេអាចប្រមូលផលស្លឹកមនបាន ២០តោន ក្នុងផ្ទៃដីបានដាំ ១ហិកតា ហើយអាចទទួលត្រលប់មកវិញដោយផលិតបានសំបុកដង្កូវនាងជាមធ្យម ១០០០គីឡូក្រាម និងផលិតបានជាសរសៃសូត្រចំនួន ១៥០ គីឡូក្រាម។ ដោយធ្វើការប្រៀបធៀបតម្លៃជាមួយដំណាំដទៃទៀត វាត្រូវបានគេប៉ាន់ស្មានថា តម្លៃរបស់សូត្រដែលផលិតបានជាក់ស្តែងច្រើនជាងតម្លៃរបស់ស្រូវ និងតម្លៃរបស់ដំណាំដទៃទៀត។

## ២.ស្ថានភាពទូទៅនៃដំណាំមន

មនដុះលូតលាស់ល្អនៅតំបន់មានអាកាសធាតុមិនត្រជាក់ខ្លាំង ប៉ុន្តែវារីកសាយភាយយ៉ាងទូលំទូលាយនៅក្នុងតំបន់ និងលាតសន្ធឹងពីតំបន់ត្រូពិកទៅតំបន់ត្រជាក់បង្គួរ។ តំបន់ដែលបានរីកដុះដាលច្រើនជាងគេគឺ តំបន់អាស៊ី រួមមាន កូរ៉េ ចិន និងជប៉ុន ហើយអនុវត្តតាមដោយតំបន់អាស៊ីអាគ្នេយ៍ភាគកណ្តាល អាស៊ីខាងកើត និងភាគខាងត្បូងអឺរ៉ុប។

កត្តាធម្មជាតិរបស់ ដី និងអាកាសធាតុ ជាកត្តាចាំបាច់បំផុតដែលត្រូវអនុវត្តជាមួយដំណាំមនដើម្បីឱ្យមនមានភាពបន្សាំទៅនឹងបរិស្ថាន ដោយហេតុនេះហើយ ទើបមានការដាំដំណាំមននេះដើម្បីអភិវឌ្ឍចេញជាប្រភេទពូជផ្សេងៗក្នុងគោលបំណង រកពូជណាដែលមានការដុះលូតលាស់បានល្អ។ ទាំងមនដែលដុះក្នុងព្រៃនិងមនបានដាំដុះ ត្រូវបានគេបែងចែកជា ២៩ប្រភេទដំបូងគេ។ពូជដាំដុះថ្មី បានមកពីពូជមូលដ្ឋានបីប្រភេទដែលមានឈ្មោះថា *Morus Lhou* (Ser.) Koidz, *Morus alba* L.និង *Morus bombycis* Koidz។

មនមានទំនោរទៅរកការបន្សាំខ្លួនទៅនឹងលក្ខខ័ណ្ឌបរិស្ថានដោយខ្លួនឯង នៅកន្លែងដែលវាបានដាំដុះ។ ពូជមួយដែលគេទទួលស្គាល់ល្អបំផុតសម្រាប់ការដាំដុះនៅតំបន់ពិសេសមួយ មិនអាចបញ្ជាក់ថា ជាពូជដែលផ្តល់ផលល្អនៅតំបន់ដទៃទៀតបានទេ។ ដូច្នេះចំណេះដឹងអំពីពូជនីមួយៗ វាចាំបាច់សម្រាប់ការជ្រើសរើសយកពូជណាដែលសមស្របនៅតំបន់នោះ។

## ២.១ ដើមកំណើត និងប្រវត្តិដំណាំមន

ប្រទេសចិនជាប្រទេសដំបូងគេ ដែលបានចិញ្ចឹមដង្កូវនាង និងដាំដំណាំមន ហើយបានស្រាវយកសរសៃសូត្រ ពីសំបុកដង្កូវនាង ជាង៥០០០ឆ្នាំមកហើយ និងជាប្រទេសផលិតសូត្រធំជាងគេនៅក្នុងពិភពលោកយើងនេះ។ បន្ទាប់ពី១០០០ឆ្នាំកន្លងមក ដំណាំមនបានរីករាលដាលទៅអាស៊ីកណ្តាល និងអឺរ៉ុប។ ពីសតវត្សរ៍ទី៩ដល់១១ ដំណាំមនបានរីករាលដាលដល់ប្រទេសអេស៊ីប អាហ្វ្រិកខាងជើង អេស្ប៉ាញ Sicily និងភាគខាងត្បូងរុស្ស៊ី។ ពីសតវត្សរ៍ទី១២ដល់១៣បានរីករាលដាលដល់ប្រទេសអ៊ីតាលី និងសតវត្សរ៍ទី១៥ រីករាលដាលដល់ប្រទេសបារាំង។ ប្រទេសកូរ៉េបានអភិវឌ្ឍន៍វិស័យសូត្រ និងដាំដំណាំមនជាង៣០០០ឆ្នាំមកហើយ ឯប្រទេសជប៉ុនវិញបានអភិវឌ្ឍន៍វិស័យនេះ ៣០០ឆ្នាំក្រោយប្រទេសកូរ៉េ។ ប្រទេសឥណ្ឌានិងប្រទេសនៅអាស៊ីអាគ្នេយ៍ រួមទាំងប្រទេសឥណ្ឌូនេស៊ី បានអភិវឌ្ឍន៍វិស័យសូត្រនៅដើមនៃគ្រិស្តសករាជ ។ នៅទ្វីបអាមេរិក បានរីកចំរើននៅវិស័យសូត្រនាឆ្នាំ១៥២២ក្នុងនោះមានសហរដ្ឋអាមេរិក និងប្រេស៊ីល(FAO Agricultural Services Bulletin73/2)។

## ២.២ ស្ថានភាពដំណាំមននៅលើពិភពលោក

ប្រទេសសំខាន់ៗនៅលើពិភពលោកដែលមានដាំដំណាំមន:

- ទ្វីបអាស៊ី មាន: ប្រទេស ចិន ជប៉ុន ឥណ្ឌា កូរ៉េ អ៊ីរ៉ង់ តួគី វៀតណាម បង់ក្លាដេស ស៊ីរី ឥណ្ឌូនេស៊ី អាហ្គានីស្ថាន លីបង់ ឡាវ ភូមា កម្ពុជា ថៃ ប៉ាគីស្ថាន និង អ៊ីរ៉ាក់។
- ទ្វីបអឺរ៉ុបមាន: ប្រទេសរុស្ស៊ី ប៊ុលហ្គារី រ៉ូមានី អ៊ីតាលី ក្រិក អេស្បាញ ហុងហ្គារី យូហ្គោស្លាវី ប៉ូឡូញ អាល់បានី ឆេកូស្លូវាគី បារាំង និងអាឡឺម៉ង់។
- ទ្វីបអាហ្វ្រិកមាន: ប្រទេស អេស៊ីប កុងហ្គោ ម៉ាដាហ្គាស្កា នីស៊េរីយ៉ា សាធារណៈរដ្ឋអាហ្វ្រិកកណ្តាល អាល់ស៊េរី តង់ស៊ានី ម៉ារ៉ូក្កូ និង ហ្គាណា
- អាមេរិកឡាទីនមាន: ប្រទេស ប្រេស៊ីល ប៉ារ៉ាហ្គាយ កូឡុំប៊ី អាស៊ង់ទីន អេក្វាដរ័ និងកូស្តារីកា(FAO Agricultural Services Bulletin73/2)។

## ២.៣ ស្ថានភាពដំណាំមននៅប្រទេសនៅកម្ពុជា

ការដាំដំណាំមន និងការត្បាញសូត្រ ត្រូវបានអនុវត្តនៅប្រទេសកម្ពុជាចាប់តាំងពីសតវត្សទី១៣មក។ បន្ទាប់ពីសង្គ្រាមលោកលើកទី២ កោសេយ្យវប្បកម្មនៅប្រទេសកម្ពុជាត្រូវបានអភិវឌ្ឍន៍ដោយមានការដាំដុះដំណាំមនលើផ្ទៃដីប្រហែល ៦០០០ហិកតា។ នៅទសវត្សឆ្នាំ១៩៦០ ប្រទេសកម្ពុជាអាចផលិតសរសៃសូត្របានចំនួន ២០តោន/១ឆ្នាំ ខណៈដែលតម្រូវការសម្រាប់ជាតិសរុបប្រចាំឆ្នាំ ៨០តោន/១ឆ្នាំ។

នៅកំឡុងពេលរបបខ្មែរក្រហម (ឆ្នាំ១៩៧៥-១៩៧៩) ផលិតផលសរសៃសូត្រ និងសកម្មភាពត្បាញ ត្រូវបានបាត់បង់ស្ទើរគ្មានសល់។ បន្ទាប់ពីសម័យរបបខ្មែរក្រហមនេះ ប្រជាជនដែលមានចំណេះដឹងក្នុងការចិញ្ចឹមដង្កូវនាងពីមុន ចាប់ផ្តើមសកម្មភាពនេះឡើងវិញ ប៉ុន្តែទទួលបានទិន្នផលតិចតួចបំផុត។ ចាប់ពីឆ្នាំ១៩៨០សកម្មភាពត្បាញក្នុងប្រទេសកម្ពុជាបាន

ចាប់ផ្តើមសារជាថ្មី ដោយផ្តោតសំខាន់លើការត្បាញសូត្រដែលនាំចូលពីប្រទេសវៀតណាម (គង់សំអឿន,២០១០)។

នៅពេលបច្ចុប្បន្ន ផលិតផលសរសៃសូត្រ និងការត្បាញគឺជាសកម្មភាពចំបងក្នុងអនុវិស័យនេះ។ ទោះបីជាយ៉ាងណាក៏ដោយ ផលិតកម្មសរសៃសូត្រដែលសំខាន់មានតែនៅភ្នំស្រុក ក្នុងខេត្តបន្ទាយមានជ័យប៉ុណ្ណោះ (ដាំមនលើផ្ទៃដីប្រហែល ១០០ហិកតា និងត្រូវបានកំពុងថយចុះនាពេលបច្ចុប្បន្ន) ដែលត្រូវបានចាត់ទុកជា មជ្ឈមណ្ឌលកោសេយ្យវប្បកម្មប្រពៃណី។ ការដាំដុះមនថ្មីៗ ត្រូវបានចាប់ផ្តើមអនុវត្តនៅខេត្តកំពត និងខេត្តសៀមរាប ដោយវិស័យឯកជន។ ផលិតផលសរសៃសូត្រប្រចាំឆ្នាំត្រូវបានគេប៉ាន់ស្មានថាមានតិចជាង៥តោន។ តម្បាញសូត្រមានសកម្មភាពកាន់តែកើនឡើងៗនៅតាមតំបន់ជនបទ ដោយសារការកើនឡើងនូវតម្រូវការក្រណាត់សូត្រនៅពីទីផ្សារក្នុងស្រុកក៏ដូចជាទីផ្សារអន្តរជាតិ។ ភ្ញៀវទេសចរបានកើនឡើងយ៉ាងគំហុក ហើយសកម្មភាពត្បាញមាននៅក្នុងខេត្តមួយចំនួនដូចជា ខេត្តតាកែវ (ស្រុកសំរោង ស្រុកបាទី និងស្រុកព្រៃកប្បាស) ខេត្តកំពង់ចាម (ព្រែកចង្ក្រាន) ខេត្តព្រៃវែង (ស៊ីធរកណ្តាល) ខេត្តបន្ទាយមានជ័យ (ភ្នំស្រុក) និងក្នុងខេត្តសៀមរាប។ នៅឆ្នាំ ២០០១ត្រូវបានគេប៉ាន់ស្មានថាមានអ្នកត្បាញប្រហែល ១០០០០គ្រួសារ ក្នុងប្រទេសកម្ពុជា ( គង់សំអឿន,២០១២ ) ។

### ២.៤ សារៈប្រយោជន៍ដំណាំមន

ដំណាំមនមិនមែនជាដំណាំគ្រាន់តែសម្រាប់យកស្លឹកមកចិញ្ចឹមដង្កូវនាងមួយមុខទេ តែស្លឹកមន គេអាចយកទៅកែច្នៃធ្វើជា តែ សម្រាប់កាត់បន្ថយជាតិស្ករក្នុងឈាម។ ជាងនេះទៅទៀត ផ្លែរបស់វា គេអាចហូបស្រស់ ឬក៏កែច្នៃធ្វើទឹកផ្លែឈើស្រស់ ទឹកផ្លែឈើកំប៉ុងបានជាច្រើនប្រភេទ ជាស្រាក្រហម និងធ្វើជាអាហារសម្រាប់អវកាសយានិកទៀតផង រីឯសំបកនៃដើមមនគេយកទៅកែច្នៃជាក្រណាត់សម្រាប់ធ្វើសំលៀកបំពាក់បានទៀត។



### ២.៥ ពូជដំណាំមន

នៅក្នុងប្រទេសកម្ពុជាយើងសព្វថ្ងៃមានពូជមនចំនួន **២៤ពូជ** កំពុងតែមានវត្តមានដាំនៅក្នុងប្រទេសកម្ពុជាទាំងពូជក្នុងស្រុក និងពូជនាំចូលដែលពូជទាំងនោះមានដូចខាងក្រោម

- ពូជក្នុងស្រុកចំនួន **៩ពូជ** មានដូចជា ពូជល្អុង ពូជកែវ ពូជបាយ ពូជសំពៅ ពូជប្រាសាក់ ពូជBR4 Salun ពូជKhun Pay2 ពូជCanva និងពូជNM60។
- ពូជនាំចូលពីប្រទេសកូរ៉េមានចំនួន **១២ពូជ** ដូចជា ពូជSuwon ពូជchongil ពូជSuhon ពូជSuseong ពូជDaryung ពូជSangil ពូជMilseong ពូជSange ពូជGeomseol ពូជShinil ពូជYeongchun និងពូជKoeryan។
- ពូជនាំចូលពីប្រទេសវៀតណាមមានចំនួន **៣ពូជ** ដូចជា ពូជLimdong1 ពូជLimdong2 និងពូជLimdong3។ (គង់សំអឿន,២០១២)

### ២.៦ ទិន្នផលស្លឹក

កត្តាដែលចូលរួមចំណែកដល់ការផ្តល់ទិន្នផលស្លឹកមនគឺ ចំនួនមែក ទំហំស្លឹក ចំនួន និងកំរាស់របស់ស្លឹកមន និងប្រវែងរបស់ចន្លោះថ្នាំង។ កត្តាទាំងនេះគួរត្រូវត្រួតពិនិត្យដើម្បីបង្កើនសមត្ថភាពផលិតស្លឹករបស់ដំណាំមន។ តាមរយៈការសិក្សាបង្ហាញថា ទិន្នផលស្លឹកមនអាស្រ័យលើចំនួននិងប្រវែងសរុបរបស់មែក និងទម្ងន់ស្លឹករបស់វា។

### ២.៧ គុណភាពស្លឹក

ជាទូទៅគុណភាពស្លឹកមនមានឥទ្ធិពលលើការលូតលាស់ទាំង៥ដំណាក់កាល របស់ដង្កូវនាង ជាពិសេសលើគុណភាពសរសៃសូត្រ។ ដើម្បីវាយតម្លៃគុណភាពស្លឹករបស់ពូជមនមួយ ក្នុងការអនុវត្ត គេកំណត់លទ្ធផលបន្ទាប់ពី ស្រាវសូត្រដង្កូវនាង ជាជាងការពិនិត្យសារធាតុគីមីដែលមានក្នុងស្លឹកមន។

### ២.៨ ភាពស៊ាំនៃជំងឺ និងគ្រោះធម្មជាតិ

មានជម្ងឺផ្សេងៗគ្នាជាច្រើនកើតលើដើមមនពាសពេញប្រទេសកូរ៉េ។ ជម្ងឺដែលធ្ងន់ធ្ងរជាងគេមានឈ្មោះថាជម្ងឺគៀបក្រិន។ ជម្ងឺនេះបណ្តាលអោយខូចផ្នែកដើមមន (die-back) និងរលួយឫស។ ដើមមនក៏ងាយរងការប៉ះពាល់ដោយគ្រោះធម្មជាតិផងដែរ ដូចជាការបំផ្លាញដោយ អាកាសធាតុត្រជាក់ រាំងស្ងួត ខ្យល់ខ្លាំង និងកង្វះពន្លឺ។ ការបង្កាត់មនដែលធន់ទ្រាំនឹងគ្រោះ ធម្មជាតិ និងជំងឺជាចំណុចមួយដែលគួរយកមកពិចារណាឱ្យបានខ្ពស់។

## ៣.លក្ខខ័ណ្ឌបរិស្ថាននៃដំណាំមន

### ៣.១ សីតុណ្ហភាព

ដំណាំមនអាចដាំដុះនិងលូតលាស់បាននៅសីតុណ្ហភាពចន្លោះពី ១៣-៣៨អង្សាសេ តែសីតុណ្ហភាពដែលល្អបំផុតសម្រាប់ការលូតលាស់គឺ ២៤-២៨អង្សាសេ (FAO agricultural services bulletin 80)។

### ៣.២ ពន្លឺ

ដំណាំមនត្រូវការពន្លឺពី ៩-១៣ ម៉ោង/១ថ្ងៃ(FAO agricultural services bulletin 80)។

### ៣.៣ សំណើម

ដំណាំមនត្រូវការសំណើមបរិយាកាសពី ៦៥-៨០% សម្រាប់ការលូតលាស់ (FAO agricultural services bulletin 80)។

### ៣.៤ តម្រូវការទឹក

ដំណាំមនអាចដាំដុះបាននៅតំបន់ដែលមានកំពស់ទឹកភ្លៀងជាមធ្យមប្រចាំឆ្នាំ ៦០០-២៥០០ម.ម/១ឆ្នាំ(FAO agricultural services bulletin 80)។

### ៣.៥ ដី

ដំណាំមនអាចដុះលូតលាស់បានលើដីភាគច្រើនបំផុត ប៉ុន្តែវាដុះលូតលាស់ល្អលើដីដែលមានជីជាតិ ដីមិនជាំទឹក ដែលមាន pHពី ៥,៥ - ៧,0 (Buckingham,2010)។

## ៤.លក្ខណៈរូបសាស្ត្រនៃដំណាំមន



### ៤.១ លក្ខណៈដើម

ដើមមនពេលនៅខ្ចីដុះលូតលាស់រាងដូចធ្មឹស ប៉ុន្តែបន្ទាប់មកនឹងដុះលូតលាស់យឺត និងកំរមានដល់កំពស់ ១០-២០ ម ណាស់(wikipedia.org)។

### ៤.២ លក្ខណៈស្លឹក



ស្លឹកមនជាប្រភេទស្លឹកឆ្លាស់ ស្លឹកពេញ មានទងស្លឹកញឹក ហើយជាទូទៅទងស្លឹកនេះមានច្រើននៅពេលដើមត្រួយលាស់ថ្មី ជាងនៅលើដើមមានមែកចាស់ ហើយមានរាងដូចធ្មេញរណារនៅតាមគែមស្លឹក(wikipedia.org)។ ស្លឹកដើរតួរដូចជារោងចក្រ ជាអ្នកផលិតកាបូនអ៊ីត្រាតពីកាបូនឌីអុកស៊ីត ទឹក និងពន្លឺព្រះអាទិត្យ។ ស្លឹកក៏ជាអ្នកសំយោគសារធាតុផ្សេងៗដែលដើមត្រូវការ។ការលូតលាស់របស់ពន្លកត្រួយជាមធ្យមប្រចាំថ្ងៃនៅខែស្លឹកឈើលាស់ ៣ស.ម និងរដូវក្តៅ ១ស.ម (FAO agricultural services bulletin 80)។

### ៤.៣ លក្ខណៈផ្កា



ផ្កាមនរាងខ្លី មានពណ៌បៃតង សំយ៉ុងចុះក្រោមនៅជាចង្កោមមិនច្បាស់លាស់ដែលមាននៅតាមអ័ក្សនៃមែកដែលលាស់ពីរដូវថ្មី និងតាមថ្នែកនៃមែកចាស់។ពួកវាដំណើរលំអងតាមរយៈខ្យល់ហើយការដាំដុះ ខ្លះអាចផលិតផ្លែដោយមិនបាច់ឆ្លងកាត់ការដំណើរលំអង។ដំណើរលំអងកាត់គឺមិនចាំបាច់ទេ។ នៅកាលីហ្វូញ៉ាការដាក់ផ្លែ ដោយមិនមានការដំណើរលំអងទេ (crfg.org) ។



### ៤.៤ លក្ខណៈផ្លែ

ផ្លែមនគឺការផ្សំឡើងនៃពហុផ្លែ ដែលមានប្រវែងពី ២-៣ ស.ម។ ផ្លែពេញវ័យមានពណ៌ ស ពណ៌បៃតង ឬពណ៌លឿងស្លេក។ ពូជភាគច្រើនផ្លែប្រែពណ៌ជាផ្កាឈូក

និងបន្ទាប់ ទៅជាពណ៌ក្រហមពេលចាប់ផ្ដើមទុំ ហើយក៏ទៅជាពណ៌ស្វាយ ឬខ្មៅនិងមានរសជាតិផ្អែមពេលវាទុំពេញលេញ។ ពេលយើងយកគ្រាប់មនពីផ្លែពណ៌សទៅដាំ យើងនឹងទទួលបានផ្លែវាពណ៌សដែរនៅពេលទុំ ផ្លែនេះក៏ផ្អែមដែរ តែមិនផ្អែមខ្លាំងដូចផ្លែមានពណ៌ខ្មៅទេ(wikipedia.org)។

### ៤.៥ លក្ខណៈឬស



ឫសដំណាំមនដែលស្រូបយកខ្យល់ សារធាតុចិញ្ចឹម និងទឹកគឺឫសចំហៀងឬ ឫសដុះផ្ដេកស្របផ្ទៃដី។ ដំណាំមនជារុក្ខជាតិមានឫសក្រាស់ ហើយរាលដាលទៅចំហៀងស្របផ្ទៃខាងលើដីពីដើមមន និងមានជំរៅត្រឹម ២៥អ៊ិញ ពីផ្ទៃខាងលើនៃដី។ ក្រៅពីមានឫសចំហៀងស្របផ្ទៃដីច្រើន ដើមមនក៏មានឫសដុះតាមចំហៀងតូចៗដែរ ដែលឫសទាំងនេះដុះចុះក្រោម ដើម្បីរក្សាលំនឹងរបស់ដើម(crfg.org)។

## ៥. ការបន្តពូជរបស់ដំណាំមន

វិធីសាស្ត្របន្តពូជរបស់ដំណាំមនអាចប្រព្រឹត្តទៅបានតាមរយៈគ្រាប់ និងតាមរយៈសរីរាង្គលូតលាស់។ យើងអាចយកគ្រាប់មនមកបណ្ដុះដាំ តែវាត្រូវការរយៈពេលយូរ និងមិនសូវល្អដូចការបន្តពូជតាមរយៈសរីរាង្គលូតលាស់។ ការបន្តពូជដោយសរីរាង្គលូតលាស់គឺជាការដាំផ្ទាល់នឹងដីតែម្ដង។ ការធ្វើបែបនេះធ្វើឲ្យកូនថ្មី ដែលបានដាំមានលក្ខណៈឯកសណ្ឋានភាពនៅក្នុងចំការ។ វិធីសាស្ត្របន្តពូជដោយសរីរាង្គលូតលាស់មានដូចជា ការបំបៅ ការសាកមែក និងការកាត់មែកដាំ។ ការបំបៅជាវិធីសាស្ត្រពេញនិយមដែលគេអនុវត្តនៅប្រទេសមានសីតុណ្ហភាពក្ដៅបង្គួរ និងវិធីសាស្ត្រកាត់មែកដាំពេញនិយមនៅតំបន់ស៊ុបត្រូពិច។














## ៦. ការបង្កើតចំការដំណាំមន

### ៦.១ វិធីសាស្ត្រដាំ

វិធីសាស្ត្រដាំមនអាស្រ័យលើលក្ខខ័ណ្ឌអាកាសធាតុ និងដីនៅតាមតំបន់នីមួយៗ។ យើងត្រូវរៀបចំថ្នាលសម្រាប់ដាំដំណាំមនឱ្យបានល្អត្រឹមត្រូវ។

**ក. ការរៀបចំរណ្តៅ:** ពេលវេលាដែលល្អបំផុតសម្រាប់បង្កលក្ខណៈដីឱ្យបានល្អប្រសើរ គឺនៅពេលរៀបចំដីសម្រាប់ដាំ។ យើងត្រូវគិតដល់លក្ខខ័ណ្ឌសម្រាប់ឱ្យឫសដំណាំមនអភិវឌ្ឍន៍បានល្អ។ ត្រូវជីករណ្តៅឱ្យធំ ហើយត្រូវដាក់សារធាតុសរីរាង្គនៅបាតរណ្តៅ យកឫសដែលកើតជំងឺ និងរលួយចេញមុនដាំវាទៅក្នុងរណ្តៅ ។ វិធីនេះនឹងធ្វើឱ្យមនដុះលូតលាស់ល្អ និងមានសុខភាពល្អទៀតផង។

**ខ. ការដាំ:** ជ្រើសរើសកូនមនដែលមានទំហំប៉ុនៗគ្នាមកដាំ ដើម្បីធានាថាវាដុះលូតលាស់បានស្មើៗគ្នានៅក្នុងចំការ។ ដាក់កូនមនចូលក្នុងរណ្តៅ និងត្រូវជៀសវាងកុំឱ្យឫសមនប៉ះផ្ទាល់ជាមួយជីធម្មជាតិដែលយើងដាក់នៅបាតរណ្តៅ រួចលប់បំពេញដីពីលើ។

**គ. ប្រភេទនៃការដាំមន**

មានការដាំមនពីរប្រភេទគឺប្រភេទដាំតែមួយជួរ និងដាំជាពីរជួរ (គូ)។

**ប្រភេទដាំមួយជួរ:** មនត្រូវបានដាំចន្លោះជួរ និងចន្លោះគុម្ពស្មើៗគ្នាទាំងអស់ក្នុងចំការ។

**ប្រភេទដាំជាពីរជួរ:**ត្រូវបានគេដាំឆ្លាស់គ្នាពីជួរមួយទៅជួរមួយម្តងទូលាយ ម្តងចង្អៀត និងផ្សំឡើងពី ២-៣ ឬច្រើនជួរ។ វិធីសាស្ត្រនេះគឺជាវិធីសាស្ត្រដែលគេពេញនិយមភាគច្រើន។

**ឃ. ចន្លោះគុម្ព:** ចន្លោះគុម្ពសម្រាប់ដាំមនគឺវាអាស្រ័យលើលក្ខខ័ណ្ឌរូបសាស្ត្ររបស់ពូជ និងលក្ខខ័ណ្ឌរបស់ដីនៅតំបន់សម្រាប់ដាំនោះ។

**ង. ការកំណត់ចន្លោះគុម្ពផ្អែកលើវិធីសាស្ត្រកាត់**

| | ទំរង់ | ប្រភេទ | ចន្លោះជួរ(m) | ចន្លោះគុម្ព(m) | កំណត់សំគាល់ |
|---|---|---|---|---|---|
| តំបន់ក្តៅបង្គួរ | កាត់ទាប | មួយជួរ | 1.5-1.8 | 0,5-0.8 | ប្រភេទចាស់ |
| | | ជួរមានដើមគូរ | ចន្លោះធំ1.8<br>ចន្លោះតូច0.6 | 0.5 | អនុសាសន៍ថ្មីៗ |
| | កាត់មធ្យម | មួយជួរ | 2-2.5 | 0.8-1.2 | |
| តំបន់ត្រូពិច | កាត់ទាប | ប្រព័ន្ធរណ្តៅ<br>ប្រព័ន្ធជួរ | 0.9-0.75<br>0.4-0.6 | 0.9-0.75<br>0.5-0.6 | |


























## ៦.២ ការអនុវត្តនៅតំបន់ត្រូពិច

តំបន់ត្រូពិចសើមដែលមានសីតុណ្ហភាពខ្ពស់ មានភ្លៀងធ្លាក់ជាប្រចាំ និងដីមមោកមានជីជាតិ គឺជាកន្លែងមានលក្ខខ័ណ្ឌសមស្របសម្រាប់ការលូតលាស់របស់ឫសតាមវិធីសាស្ត្រកាត់ដាំ។ មានពូជក្នុងស្រុកមួយចំនួនដែលអាចលូតលាស់បានយ៉ាងល្អក្នុងលក្ខខ័ណ្ឌបែបនេះ។ ការកាត់ផ្នែកនៃមែកមកដាំអាចផលិតជាកូនមនបាន។

### ក. វិធីសាស្ត្រ

ការកាត់មែកដាំ: កំឡុងពេលរដូវវស្សាគឺជាពេលវេលាល្អបំផុតដើម្បីអនុវត្តការកាត់មែកយកដាំ។ ប្រសិនបើមានទឹកច្រើនសមស្របពេញមួយឆ្នាំ យើងអាចអនុវត្តវិធីនេះពេលណាក៏បាន។

ការដាំ: ក្នុងកំឡុងពេលរដូវភ្លៀង ការកាត់មែកអាចដាំដោយផ្ទាល់លើដីចំការតែម្តង។ រណ្តៅដែលបានដាក់ជីកំប៉ុស្តរួចនឹងជួយបង្កើនការដុះលូតលាស់របស់កូនមនបានយ៉ាងល្អ។

## ៧. ការពត់រាង(ការតាក់តែងដើមឆ្នាំដំបូង)

ការពត់រាងរបស់ដើមមន ចន្លោះគុម្ពសមស្រប និងវិធីសាស្ត្រប្រមូលផលសមស្រប មានឥទ្ធិពលទៅលើទិន្នផលស្លឹកមន។

### ៧.១ ទំរង់នៃការកាត់ទាប:

វិធីសាស្ត្រនេះគឺជាទូទៅត្រូវបានគេណែនាំឱ្យប្រើប្រាស់ លើកលែងតែកន្លែងដែលមានភ្លៀង ឬព្រិលច្រើន ដែលវានឹងបណ្តាលអោយស្លឹកខាងក្រោមខូច។




### ៧.២ ការពត់រាង(ការតាក់តែងដើម)ក្នុងករណីដែលការដាំផ្អៀង

#### ក. នៅចន្លោះ១-៤ ខែបន្ទាប់ពីដាំ

- បន្ទាប់ពីការដាំមែកដែលកាត់នោះហើយដើមនីមួយៗគួរតែទុកឱ្យដុះតែពន្លកត្រួយតែមួយដែលយើងរំពឹងថាវានឹងក្លាយជាដើមមេ។

- នៅពេលវាលូតលាស់បានកំពស់ ១ម នៅអាយុ៩ខែ ឬយូរជាងនេះ វាត្រូវបានកាត់ទុកឱ្យនៅត្រឹមតែប្រវែង១៥ស.ម ពីដី។
- ផ្នែកដែលនៅសល់ក្លាយជាដើមមេដែលមានភ្នែក ៣-៤នឹងត្រូវដុះចេញជាពន្លកថ្មីពេលក្រោយ។

**ខ. ចាប់ពីអាយុ៩ខែបន្ទាប់ពីដាំ**

- បន្ទាប់ពីពន្លកថ្មីនោះមានកំពស់ប្រវែង ១ម គឺនៅអាយុប្រហែល៩ខែបន្ទាប់ពីដាំពន្លកខ្ចី៣ត្រូវបានជ្រើសរើសចេញពីពន្លកដែលដុះលូតលាស់ល្អនោះ ត្រូវកាត់ទុកកំពស់ ១០ស.ម ពីដី ចំពេលប្រមូលផលលើទីមួយ។
- វិធីកាត់ប្រភេទនេះ ពន្លកខ្ចីនៅផ្នែកខាងលើនៃដើមត្រូវបានកាត់បន្តិចម្តងៗខ្ពីឡើងៗ និងផ្នែកខាងក្រោមនៃដើមកាន់តែវែងបន្តិចម្តងៗ ដូច្នេះកំពូលរបស់ត្រួយទាំង៣នោះគឺមានលក្ខណៈស្មើតែប្រហាក់ប្រហែលខាងលើដី។
- នៅពេលដើមវាផលិតច្រើនជាង៣ត្រួយ ត្រួយ៣ដែលធំជាងគេត្រូវទុកវា ហើយត្រួយផ្សេងទៀតត្រូវកាត់ចោលឱ្យត្រឹមដើម។
- ក្នុងករណីដែលដើមមិនសូវលូតលាស់ ការអនុវត្តបែបនេះត្រូវពន្យារពេលរយៈពេល២-៣ខែ។

## ៨. ការតាក់តែងមែក

ការតាក់តែងមែកបានត្រឹមត្រូវគឺជាកត្តាសំខាន់ដើម្បីថែរក្សាផ្នែកខាងលើរបស់ដើមមនសម្រាប់ការបែកមែកដ៏មានប្រសិទ្ធភាព។ មែកល្អនឹងផលិតបានទិន្នផលស្លឹកខ្ពស់ និងដើមដែលបានពត់រាងរួចនឹងធ្វើឱ្យដើមមើលឃើញស្អាត។

**៨.១ ប្រភេទនៃការតាក់តែង**



| រាងដូចកណ្តាប់ដៃ | | រាងមិនដូចកណ្តាប់ដៃ |
|---|---|---|
| ធ្វើឱ្យភ្នែកមិនទាន់ដុះចាប់ផ្តើមដុះនៅក្បែរគល់<br>ពន្លកតិចតែរឹងមាំ<br>ងាយស្រួលពត់រាង<br>និងគ្រប់គ្រងសត្វល្អិតចង្រៃ | ពន្លកសម្រាប់ដុះជាមែក<br>កន្លែងដែលត្រូវកាត់<br>ចំនួនរបស់មែកដុះលូតលាស់<br>សម្រាប់អនុវត្តការដាំដុះ | ភ្នែកធម្មតា ១០ស.ម ខាងលើគល់<br>មែកច្រើនតែខ្សោយ<br>ពិបាកនឹងកំណត់រាង |

### ៨.២ គោលការណ៍កែសម្រួលដើមដែលនៅសល់

| ការកាត់វែង (ទុក ៣-៥ម) | កាត់ខ្លី(ក្បែរគល់) |
|---|---|
| មែកនៃដើមនៅខ្ចី<br>មែកមានទំហំធំ<br>មែកផ្នែកខាងលើ<br>មែកនៃដើមដែលខ្លាំង | មែកនៃដើមចាស់<br>មែកមានទំហំតូចៗ<br>មែកនៅខាងក្រោម<br>មែកនៃដើមខ្សោយ |

### ៨.៣ វិធីសាស្ត្រកាត់មែក

ដើម្បីកែសម្រួលមែកដែលនៅសល់ មែកត្រូវកាត់ឱ្យបានសមស្របដូចខាងក្រោមៈ




## ៩. ការប្រើប្រាស់ជី

បរិមាណ និងភាពញឹកញាប់នៃការប្រើប្រាស់ជីអាស្រ័យលើការលូតលាស់របស់ដើមមន ការតាក់តែងមែក វិធីសាស្ត្រប្រមូលផល ទឹកភ្លៀង ប្រភេទដី និងលក្ខខ័ណ្ឌអាកាសធាតុ។

**៩.១ តំបន់ត្រូពិចៈ** បរិមាណជី និងវិធីសាស្ត្រប្រើប្រាស់ត្រូវបានបង្ហាញដូចខាងក្រោមៈ

- នៅដំណាក់កាលទីI: ត្រូវប្រើ ៥០-៥០-៥០ គីឡូក្រាម/ហិកតា
- នៅដំណាក់កាលទីII: ត្រូវប្រើ ៥០-០-០ គីឡូក្រាម/ហិកតា
- នៅដំណាក់កាលទីIII: ៥០-៥០-៥០ គីឡូក្រាម/ហិកតា
- នៅដំណាក់កាលទីIV: ៥០-០-០ គីឡូក្រាម/ហិកតា
- នៅដំណាក់កាលទីV: ៥០-០-០ គីឡូក្រាម/ហិកតា




### ៩.២ វិធីសាស្ត្រប្រើប្រាស់

- ការបាចៈ នៅចំការមនដែលមានជីរាបស្មើ ជីត្រូវបានគេបាចនៅចន្លោះគុម្ពនៃដើមមន។ ដីនិងជីត្រូវលាយជាមួយគ្នាដោយប្រើចប។ វិធីសាស្ត្រនេះសមស្របសម្រាប់មនពេញវ័យ។



- ការបាចជុំវិញៈ សមស្របសម្រាប់ដីជំរាល និងមននៅក្មេង។ ត្រូវជីករណ្តៅរាក់ៗក្បែរគល់មនរួចដាក់ជីក្នុងរណ្តៅនោះនិងកប់ដីពីលើ។




- សារធាតុសរីរាង្គៈ ជីកំប៉ុស្តត្រូវដាក់ក្នុងរណ្តៅដាក់នៅចន្លោះនៃជួររបស់មន។ ចំបើងនិងជីស្រស់យកពីរុក្ខជាតិតូចៗ ឬស្លឹកឈើ អាចដាក់នៅពីលើរណ្តៅជីកំប៉ុស្តនោះ។




## ១០. ការគ្រប់គ្រងទឹក

កំពស់ទឹកភ្លៀងសមស្របប្រចាំថ្ងៃគឺ ៤-៥ម.ម នៅរដូវដុះលូតលាស់។ ការស្រោចស្រពត្រូវការអនុវត្តប្រសិនបើកំពស់ទឹកភ្លៀងទាបជាងកំរិតកំណត់។ ការស្រោចស្រពជាមធ្យមពី

២០០-២៥០t/ha រៀងរាល់ ៤-៥ថ្ងៃម្តង។ ការប្រើគម្របដីដោយសារធាតុសរីរាង្គគ្របដីអាចកាត់បន្ថយការរំហួតទឹក និងបង្កើនរន្ធសម្រាប់ផ្ទុកទឹកនៅក្នុងដីបាន។

## ១១. ការគ្រប់គ្រងស្មៅ និងវិធានការការពារ

ស្មៅប្រជែងស្រូបយកសារធាតុចិញ្ចឹម ពន្លឺ និងទឹកពីដំណាំមន។ វិធានការគីមី វិធានការមេកានិច និងវិធានការក្សេត្រសាស្ត្រ ត្រូវបានប្រើដើម្បីកំចាត់ស្មៅចង្រៃ ហើយជំរើសនៃការប្រើគឺអាស្រ័យលើកត្តាក្នុងតំបន់។

**១១.១ វិធានការគីមី:** ថ្នាំសំលាប់ស្មៅត្រូវបានបាញ់ផ្នែកខាងលើនៃផ្ទៃដីដើម្បីការពារកុំឱ្យស្មៅដុះ ឬអាចប្រើដោយផ្ទាល់លើស្មៅកំពុងលូតលាស់ ប៉ុន្តែភាពចាំបាច់បំផុតត្រូវការពារកុំឱ្យថ្នាំប៉ះស្លឹកមន។

**១១.២ វិធានការក្សេត្រសាស្ត្រ:** ចំបើង និងសារធាតុសរីរាង្គផ្សេងៗ ត្រូវបានដាក់គ្របផ្ទាល់លើដីដើម្បីការពារកុំឱ្យស្មៅដុះ ដោយសារស្មៅពុំអាចស្រូបយក ពន្លឺព្រះអាទិត្យនោះបាន។ វិធីនេះជួយបង្កើតមមោកដល់ដី និងសមស្របបំផុតសម្រាប់ដីជំរាល។ ប្រសិនបើមានសត្វល្អិតចង្រៃនៅក្នុងគំរបដីនេះយើងអាចប្រើថ្នាំសំលាប់សត្វល្អិតបាន។

## ១២. ការប្រមូលផល

មានវិធីសាស្ត្រ២យ៉ាងក្នុងការប្រមូលផលស្លឹកមន។ ជម្រើសនីមួយៗអាស្រ័យលើលក្ខខ័ណ្ឌធម្មជាតិ វិធីសាស្ត្រចិញ្ចឹមដង្កូវនាង និងការចំណាយលើពលកម្មពេលប្រមូលផល។ល។ ការជ្រើសរើសត្រួយ និងស្លឹកបន្ទាប់ពីត្រួយក៏ជាកត្តាសំខាន់សម្រាប់ចិញ្ចឹមដង្កូវនៅតូចៗ (ដំណាក់កាលទីមួយ) រីឯស្លឹកបន្តបន្ទាប់សម្រាប់ដង្កូវនៅដំណាក់កាលបន្តទៀតរហូតដល់ស្លឹកចាស់សម្រាប់ចិញ្ចឹមដង្កូវពេញវ័យនៅដំណាក់កាលទី៥មុនវាឡើងសំបុក។

**១២.១ វិធីសាស្ត្របេះស្លឹក:** វិធីសាស្ត្រនេះពិតជាត្រូវការចំណាយកំលាំងច្រើន។ ការបេះស្លឹកត្រូវបានគេធ្វើឡើងនៅរដូវភ្លៀងធ្លាក់ និងរដូវរំហើយ និងការបេះមែកត្រួយនៅកំឡុងរដូវស្លឹកឈើលាស់ដែលជារដូវចិញ្ចឹមដង្កូវនាង។

វិធីសាស្ត្រពិសេសដើម្បីបេះស្លឹកមនគឺកាំបិតជាប់ម្រាមដៃសម្រាប់កាត់ស្លឹក និងមែកស្លឹកទាំងមូល។



**១២.២ វិធីសាស្ត្រកាត់យកមែក:** វិធីសាស្ត្រនេះត្រូវបានគេណែនាំឱ្យអនុវត្តព្រោះវាមិនចំណាយកំលាំងច្រើន។ ការប្រមូលផលអាស្រ័យលើរដូវកាលនៃការចិញ្ចឹមដង្កូវនាង និងវិធីសាស្ត្រ លក្ខខ័ណ្ឌសរីរៈរបស់មន ប្រសិទ្ធភាពនៃការប្រើពលកម្ម និងការដុះលូតលាស់ពន្លកត្រួយថ្មី។






## ១២.៣ វិធីសាស្ត្រកាត់តែងមែកសម្រាប់កូនដង្កូវទើបញាស់

ស្លឹកខ្ចីទន់លូតលាស់កំឡុងពេលរដូវភ្លៀង។ ដើម្បីផលិតស្លឹកខ្ចីដែលមានគុណភាពសម្រាប់ដង្កូវនាងទើបញាស់នៅរដូវរំហើយគឺជាការចាំបាច់មួយត្រូវអនុវត្តតាមបច្ចេកទេស។ នេះគឺជាការសំខាន់ដើម្បីធានាបាននូវសំបុកដង្កូវនាងដែលមានទិន្នផលល្អ។ វិធីនេះអនុវត្តតែនៅតំបន់ក្តៅបង្គួរតែប៉ុណ្ណោះ។

វិធីសាស្ត្រកាត់ចុងត្រួយ

1. មែកមនត្រូវកាត់យ៉ាងហោចណាស់ ២ទៅ៣ខែមុនចិញ្ចឹមដង្កូវនាង
2. នៅពេលត្រួយខ្ចីលាស់បានប្រហែល ១៥ស.ម ត្រូវចាប់ផ្តើមកាត់
3. កាត់ពន្លកត្រួយ១៥ស.ម ខាងលើមែក។ បេះស្លឹកពាក់កណ្តាលផ្នែកខាងលើ ចំណែកពាក់កណ្តាលនៃផ្នែកខាងក្រោមទុក។

4. ពេលវេលាសមស្របសម្រាប់អនុវត្តវិធីនេះគឺនៅ ២០-២៥ថ្ងៃ មុនពេលដង្កូវនាងឡើងសំបុក នៅរដូវភ្លៀង ឬ ៣០-៣៥ថ្ងៃ មុនពេលឡើងសំបុកនៅរដូវប្រាំង។
5. បន្ទាប់ពីនោះ២ឬ៣ថ្ងៃ ពន្លកចំហៀងនឹងដុះចេញជាច្រើនដែលអាចសមស្របសម្រាប់កូនដង្កូវទើបញាស់។
6. បន្ទាប់ពីប្រមូលផល មែកត្រូវបានកាត់ដល់គល់ និងត្រូវដាក់ជីដល់មន។
7. ដំណាំមនប្រហែល៥០ដើមមនអាចចិញ្ចឹមដង្កូវនាងបាន១ប្រអប់






## ១៣.ប្រមូលផលនៅតំបន់ត្រូពិច និងការកាត់តែងមែក

នៅភាគច្រើននៃតំបន់ត្រូពិច ស្លឹកមនត្រូវបានប្រមូលផលតាមរយៈការបេះជាបន្តពេញមួយឆ្នាំ។ ការបេះបន្តបែបនេះធ្វើឱ្យស្លឹកមិនមានគុណភាព និងចំណាយពលកម្មច្រើន។ ការប្រមូលផលមែកមិនត្រូវបានគេទទួលយកទូលំទូលាយទេ។

**១៣.១ ចាប់ពីដាំរហូតដល់ពេលប្រមូលផលលើកដំបូង:**

ខាងក្រោមនេះបង្ហាញពីការលូតលាស់ដំបូងរបស់ដំណាំមន រហូតដល់ពេលប្រមូលផលលើកដំបូង។ នៅដំណាក់កាលនេះ មនលូតលាស់ដល់ចំណុចកំពូល និងប្រព័ន្ធដំណាំចំរុះ ត្រូវបានគេអនុវត្ត។

- បន្ទាប់ពីដាំបាន៦ខែមនដុះលូតលាស់និងចាប់ផ្ដើមបែកមែក
- នៅអាយុ ៩ខែបន្ទាប់ពីដាំ អាចប្រមូលស្លឹកមួយចំនួនសម្រាប់ចិញ្ចឹមដង្កូវនាង កាត់ផ្នែកខាងចុងដើម្បីបង្កើនការលូតលាស់ត្រួយ។
- នៅអាយុ ១១ខែបន្ទាប់ពីដាំ ប្រមូលផលស្លឹកពីមែកបន្ទាប់
- នៅអាយុ ១៥ខែបន្ទាប់ពីដាំប្រមូលផលមែកទីបី

- បន្ទាប់ពីប្រមូលផលអស់ត្រូវតាក់តែងមែក និងបន្ទាប់ពីតាក់តែងមែករួច ស្លឹកអាចប្រមូលផលបាននៅរយៈពេល ២-៣ខែ និងបន្ទាប់២-៣ខែ ដទៃទៀត។

**១៣.២ វិធីសាស្រ្តដំណាំចំរុះ**

ការប្រើវិធីនេះអាស្រ័យលើទំហំសមស្របរបស់ចំការដំណាំមន។

**១៣.៣ ការប្រមូលផល**

តារាងខាងក្រោមបង្ហាញពីចំការនីមួយៗត្រូវបានកាត់អាស្រ័យលើតម្រូវការចិញ្ចឹមដង្កូវនាង។ ចំការដែលបានកាត់ត្រូវការរយៈពេល ២-៣ខែដើម្បីដុះឡើងវិញ។

| កូនស្រែ | ទី១ | ទី២ | ទី៣ | ទី៤ | ទី៥ | ទី៦ | ទី៧ | ទី៨ | ទី៩ | ទី១០ | ទី១១ | ទី១២ |
|---|---|---|---|---|---|---|---|---|---|---|---|---|
| I | | | | | | | | | | | | |
| II | | | | | | | | | | | | |
| III | | | | | | | | | | | | |
| IV | | | | | | | | | | | | |

# ឯកសារយោង

១. គង់ សំអឿន, ២០១២.របាយការណ៍វឌ្ឍភាពស្ដីពីលទ្ធផលនៃការអនុវត្តគម្រោងគាំទ្រការស្ដារឡើងវិញវិស័យសូត្រនៅកម្ពុជា

២. គង់ សំអឿន, ២០១០.របាយការណ៍សកម្មភាពអនុវត្តការងារគម្រោងគាំទ្រការស្ដារឡើងវិស័យសូត្រនៅកម្ពុជា

៣. Dr. Sung Gyoo Byung, 2013. Sericultural & Apicultural Materials Division Department of Agricultural Biology, National Academy of Agricultural Science, RDA, Republic of Korea

៤. Alan Backingham,2010. Grow Fruit: Gardens, Yards, Bolconies, Roof terraces, page 162

៥. FAO Agricultural Services Bulletin 80,1990. Sericulture training manual

៦. FAO Agricultural Services Bulletin 73/2,1992. Silkworm rearing

៧. www.en.wikipedia.org/wiki/Morus_(Plant), 29 August 2014 at 9:40am

៨. www.crfg.org/pubs/ff/mulberry.html, 9 September 2014 at 4:20pm